## លិខិតជូនដំណឹងអំពីស្ថានការណ៍របស់ក្រសួងអប់រំ

## ការវាយតម្លៃលើជោគជ័យតាមទិសដៅប្រចាំឆ្នាំ (AMAOs) របស់ច្បាប់ Title III

ក្រសួងអប់រំ៖ **ហ្វីឡាដែលហ្វ្យ៉ា** ថ្ងៃខែ៖ ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦

ជូនចំពោះ មាតាបិតា/អាណាព្យាបាល៖

បច្ចុប្បន្ននេះ កូនលោកអ្នកបានចុះឈ្មោះរៀនក្នុងកម្មវិធីអភិវឌ្ឍភាសាអង់គ្លេស ដើម្បីជួយបង្កើនសមត្ថភាពរបស់ពួកគេក្នុងការ និយាយ សរសេរ និង ការយល់ដឹង អំពីភាសាអង់គ្លេស និងទទួលបាននូវលទ្ធផលខ្ពស់ចំពោះការសិក្សា។ គេតម្រូវឲ្យក្រសួងធ្វើឲ្យមានការកើនឡើងនូវ ចំនួន ឬ ភាគរយ នៃសិស្សានុសិស្សដែល៖

- មានការរីកចម្រើនក្នុងការរៀនភាសាអង់គ្លេស
- មានចំណេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់ ហើយ
- ធ្វើបានតាម ការវាយតម្លៃតាមទិសដៅប្រចាំឆ្នាំ (AMOs) តាមការតម្រូវនៃការវាយតម្លៃជោគជ័យក្នុងការសិក្សា របស់រដ្ឋ។

នៅរដ្ឋពិនស៊ីលវេញ៉ា ការរីកចម្រើន និងជោគជ័យ របស់សិស្ស សម្រេចតាមរយៈការប្រឡង ACCESS ប្រចាំឆ្នាំ សម្រាប់ការវាយតម្លៃចំណេះដឹងភាសាអង់គ្លេសរបស់សិស្ស ELLs®។

គោលបំណងរបស់យើងគឺផ្តល់ដំណឹងដែលទាក់ទងនឹងស្ថានការណ៍របស់ក្រសួង ដែលទាក់ទងនឹងគោលដៅផ្សេងៗដែលរដ្ឋបានកំណត់សម្រាប់កម្មវិធីអភិវឌ្ឍភាសាអង់គ្លេស។ យោងទៅលើការពិនិត្យលទ្ធផលនៃការប្រឡងរបស់សិស្សានុសិស្សដែលមានសិទ្ធិចុះឈ្មោះរៀនក្នុងកម្មវិធីរបស់ក្រសួងទាំងអស់ ក្រសួងអប់រំនៃរដ្ឋពិនស៊ីលវេញ៉ា បានរាយការណ៍ពីស្ថានការណ៍សម្រាប់សាលា ដូចតទៅ។

របាយការណ៍នេះបានផ្តល់ជូនលោកអ្នកក្នុងកំឡុងពេល៣០ថ្ងៃ នៃថ្ងៃដែលក្រសួងទទួលរបាយការណ៍អំពីស្ថានការណ៍នៃ ការវាយតម្លៃការសម្រេចតាមទិសដៅប្រចាំឆ្នាំ ពី ក្រសួងអប់រំនៃរដ្ឋពិនស៊ីលវេញ៉ា។

របាយការណ៍អំពីស្ថានការណ៍នៃឆ្នាំសិក្សា៖ **២០១៣-២០១៤**

<u>ទិសដៅទី១</u>៖ ចំនួនភាគរយនៃសិស្សានុសិស្សដែលមានការរីកចម្រើនគ្រប់គ្រាន់ក្នុងការប្រឡង ACCESS សម្រាប់សិស្សានុសិស្ស ELLs®
ទិសដៅរបស់រដ្ឋពិនស៊ីលវេញ៉ា៖ **៦១%** តើធ្វើបានតាមទិសដៅឬទេ៖ **មិនបានទេ**

<u>ទិសដៅទី២</u>៖ ចំនួនភាគរយនៃសិស្សានុសិស្សដែលទទួលបានចំណេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់ ក្នុងការប្រឡង ACCESS សម្រាប់សិស្សានុសិស្ស ELLs®
ទិសដៅរបស់រដ្ឋពិនស៊ីលវេញ៉ា៖ **២៦%** តើធ្វើបានតាមទិសដៅឬទេ៖ **បាន**

<u>ទិសដៅទី៣</u>៖ ក្រសួងធ្វើបានតាមការវាយតម្លៃតាមទិសដៅប្រចាំឆ្នាំ សម្រាប់សិស្សានុសិស្ស LEP តាមក្រុមតូចៗ នៃការប្រឡងក្នុងឆ្នាំដដែល
តើធ្វើបានតាមទិសដៅឬទេ៖ **បាន**

*(ទិសដៅទី៣អាចកត់ទុកថា "NA" (មិនជាប់ពាក់ព័ន្ធ)។ នេះមានន័យថា បើគ្មានចំនួនសិស្សានុសិស្សគ្រប់គ្រាន់ដើម្បីធ្វើការសម្រេច។ នេះអាចចាត់ទុកថាធ្វើបានតាមទិសដៅ នៅពេលណាគេរាយការណ៍ពីស្ថានការណ៍សរុប។)*

<u>សរុបជាទូទៅ</u>៖ តើក្រសួងធ្វើបានតាមទិសដៅទាំងបីនេះ ឬទេ៖ **មិនបានទេ**

សូមទាក់ទង **ការិយាល័យផ្នែក កម្មវិធីសិក្សា និងកម្មវិធីភាសាចម្រុះ** លេខ **(២១៥) ៤០០-៤២៤០ (ជ្រើសយកលេខ២)** នៅក្រសួងរបស់កូនលោកអ្នក ដើម្បីជ្រាបព័ត៌មានអំពីវិធីដែលលោកអ្នកអាចចូលរួមយ៉ាងសកម្មក្នុងការជួយកូនលោកអ្នករៀនភាសាអង់គ្លេស និងពុះពារឲ្យបាននូវការលំបាកនៃស្តង់ដានៃការសិក្សា។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ការចាប់អារម្មណ៍ និងការចូលរួម ក្នុងការអប់រំរបស់កូនលោកអ្នក។

ដោយសេចក្តីស្មោះត្រង់

Linda Long
អ្នកផ្តល់ឱវាទផ្នែកអប់រំពីរភាសា